ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៤៥/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃពិធីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម
# ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# និងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ

**ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី**

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់**ឯកឧត្តម** Dato’ Seri Anwar Ibrahim នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានអាស៊ានឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយនឹង**ឯកឧត្តម** Anutin Charnvirakul នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ បានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ ពិធីនេះក៏មានការចូលរួមធ្វើជាសាក្សីពី**ឯកឧត្តម** Donald J. Trump ប្រធានាធិបតីសហរដ្ឋអាមេរិក និង **ឯកឧត្តម** Dato’ Seri Anwar Ibrahim។

ថ្ងៃនេះត្រូវបានកត់ត្រាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ជាសារវន្ត សម្រាប់កម្ពុជា និងថៃ ដែលបានបញ្ជាក់ឡើងវិញនូវការជឿជាក់រួមគ្នានៃប្រទេសយើងទាំងពីរថា សន្តិភាពនៅតែអាចមាន ដរាបណាប្រជាជាតិនានាមានសេចក្តីក្លាហាន និងសុភវិនិច្ឆ័យក្នុងការបន្តស្វែងរកសន្តិភាពជាមួយគ្នា។

តាងនាមប្រជាជនកម្ពុជា **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**ឯកឧត្តមប្រធានាធិបតី** Donald J. Trump ក្នុងភាពជាអ្នកដឹកនាំដ៏មឺងម៉ាត់ និងការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនក្នុងការគាំទ្រសន្តិភាពជានិរន្តន៍រវាងកម្ពុជានិងថៃ និងចំពោះកិច្ចខិតខំប្រឹងប្រែងដោយមិនគិតពីការនឿយហត់ក្នុងការជួយធ្វើឱ្យសមិទ្ធផលនេះក្លាយជាការពិត។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

**សម្តេចធិបតីនាយករដ្ឋមន្ត្រី**ក៏បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់**ឯកឧត្តមនាយករដ្ឋមន្ត្រី** Anwar Ibrahim ចំពោះការគាំទ្រដោយឥតងាករេ និងការសម្របសម្រួលរបស់**ឯកឧត្តម** ក្នុងដំណើរការស្វែងរកសន្តិភាពនេះរហូតដល់ទីបញ្ចប់ប្រកបដោយជោគជ័យ។ **សម្តេចធិបតី**ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំអាស៊ាន ចិន និងប្រទេសដៃគូនានា ដែលបានគាំទ្របទឈប់បាញ់តាំងពីដើមរៀងមក។

កម្ពុជាបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តយ៉ាងពេញលេញ និងដោយភាពស្មោះត្រង់នូវសេចក្តីថ្លែងការណ៍រួមនេះ និងបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយប្រទេសថៃ និងដៃគូទាំងអស់ ដើម្បីធានាថា សន្តិភាពនេះនៅស្ថិតស្ថិរ និងនាំមកនូវផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជននៃប្រទេសយើងទាំងពីរ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**ក៏បានអំពាវនាវឱ្យមានការបន្តគាំទ្រ និងការរួមចំណែករបស់សហគមន៍អន្តរជាតិ និងដៃគូនានា ដើម្បីធានាសម្រេចបានជាផ្លែផ្កានៃសេចក្តីថ្លែងការណ៍រួមនេះ។

ឆ្លៀតក្នុងឱកាសនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** សង្ឃឹមយ៉ាងមុតមាំចំពោះការដោះលែងទាហានកម្ពុជាទាំង១៨នាក់ជាបន្ទាន់ ក្រោមហេតុផលមនុស្សធម៌ និងស្របតាមការឯកភាពគ្នាក្នុងសេចក្តីថ្លែងការណ៍រួមនេះ។

ជាចុងក្រោយ ដោយទទួលស្គាល់ការលះបង់ដ៏ធំធេង និងកិច្ចខិតខំប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់របស់**ឯកឧត្តមប្រធានាធិបតី** Donald J. Trump ក្នុងការលើកកម្ពស់សន្តិភាព មិនត្រឹមតែរវាងកម្ពុជា និងថៃប៉ុណ្ណោះទេ ថែមទាំងក្នុងចំណោមប្រជាជាតិទាំងឡាយ និងដើម្បីបង្ហាញនូវការដឹងគុណរបស់ប្រជាជនកម្ពុជា **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានប្រកាសស្នើបេក្ខភាព**ឯកឧត្តមប្រធានាធិបតី** Trump សម្រាប់ពានរង្វាន់ណូបែលសន្តិភាព។

ថ្ងៃអាទិត្យ ៥កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

គួឡាឡាំពួ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 45 /2025 MFA.IC

PRESS RELEASE

**PRESS RELEASE**
**Outcomes of the Signing Ceremony of the Joint Declaration by the Prime Minister of the Kingdom of Cambodia and the Prime Minister of the Kingdom of Thailand**

26 October 2025, Kuala Lumpur, Malaysia

On 26 October 2025, at the invitation of **H.E. Dato' Seri Anwar Ibrahim**, Prime Minister of Malaysia and Chair of ASEAN for 2025, **Samdech Moha Borvor Thipadei HUN Manet**, Prime Minister of the Kingdom of Cambodia, together with **H.E. Anutin Charnvirakul**, Prime Minister of the Kingdom of Thailand, attended the Signing Ceremony of the Kuala Lumpur Joint Declaration between the Kingdom of Cambodia and the Kingdom of Thailand, in Kuala Lumpur, Malaysia. The Ceremony was also witnessed by **H.E. Donald J. Trump**, President of the United States of America and **Prime Minister Dato' Seri Anwar Ibrahim**.

Today marks a historic moment of profound significance for Cambodia and Thailand — a day that reaffirms our shared conviction that peace is always possible when nations have the courage and wisdom to pursue it together.

On behalf of the Cambodian people, **Prime Minister Hun Manet** expressed his deepest gratitude to **President Donald J. Trump** for his decisive leadership and steadfast commitment to supporting lasting peace between Cambodia and Thailand, and for his tireless efforts in helping make this achievement a reality.

**The Prime Minister** also conveyed his sincere appreciation to **Prime Minister Dato' Seri Anwar Ibrahim** for his unwavering support and facilitation throughout this peace process until its successful conclusion. He further extended appreciation to ASEAN colleagues, China, and other partners who have supported the ceasefire from the very beginning.

Cambodia reaffirms its strong commitment to fully and faithfully implementing this Joint Declaration and to continuing close cooperation with Thailand and all partners to ensure that this peace endures and brings tangible benefits to both peoples. The Prime Minister also called for the continued support and contribution of the international community and partners to ensure the fruitful realization of the Joint Declaration.

Taking this opportunity, **the Prime Minister** strongly hoped for the prompt release of the 18 Cambodian soldiers on humanitarian grounds and as agreed in the Joint Declaration.

Finally, recognizing **President Donald J. Trump**'s unwavering dedication and resolute efforts to promote peace—not only between Cambodia and Thailand but also among other nations—and reflecting the gratitude of the Cambodian people, **Prime Minister Hun Manet** announced his nomination of **President Trump** for the Nobel Peace Prize.

Kuala Lumpur, 26 October 2025